សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ

២៨ មិនា ២០១៦

- **សូមគោរព ឯកឧត្តម វ៉ាត ប៉ាវ៉ានីន អភិបាលរងខេត្តឧត្តរមានជ័យ**
- **សូមគោរព លោក សាំង ប៊ុនថេន ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តឧត្តរមានជ័យ**
- **សូមគោរព លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនពីររួមមាន "គម្រោងសាងសង់ស្ពានដងទង់ ក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ" និង "គម្រោងកែលម្អផ្លូវ ក្នុងឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ" ។

ជំនួយទីមួយនេះ ដែលមានថវិកាសរុបចំនួន ៩០,៣៥០ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តឧត្តរមានជ័យ សម្រាប់ការសាងសង់ស្ពានបេតុងថ្មីមួយប្រវែង ១៥ម៉ែត្រ ក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់ប្រជាពលរដ្ឋប្រមាណជា ៣,៤០០នាក់ដែលរស់នៅក្នុងតំបន់នេះ។ ខ្ញុំសង្ឃឹមថា ស្ពានបេតុងថ្មីមួយនេះ នឹងរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចក្នុងស្រុកតាមរយៈការផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់សាលារៀន មន្ទីរពេទ្យ ផ្សារ និងតំបន់ដទៃទៀតផងដែរ។

ជំនួយទីពីរនេះ ដែលមានថវិកាសរុបចំនួន ៨៧,៤៧១ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ ដោយធ្វើការសាងសង់ផ្លូវគ្រួសក្រហមប្រវែង ៤,០០០ម៉ែត្រ និងលូចំនួន ៦ ក្នុងខេត្តព្រះវិហារ។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់ភាពងាយស្រួលកាន់តែប្រសើរដល់ប្រជាពលរដ្ឋប្រមាណជា ៣,២០០នាក់ ក្នុងការធ្វើដំណើរទៅកាន់ទីកន្លែងសំខាន់ៗដូចជា សាលារៀន មន្ទីរពេទ្យ និងផ្សារជាដើម។

វិស័យដឹកជញ្ជូន គឺជាវិស័យដ៏ចាំបាច់សម្រាប់សុខាមាលភាពរបស់ប្រជាជនកម្ពុជា។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យនេះ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជានៅក្នុងវិស័យនេះ តាមរយៈជំនួយផ្នែកហិរញ្ញប្បទាន និងជំនួយផ្នែកបច្ចេកទេស ក្នុងនោះរួមមាន គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិជាដើម។

ខ្ញុំសង្ឃឹមថា គម្រោងទាំងពីរនេះ ដែលបានចុះកិច្ចសន្យាផ្តល់ជំនួយនៅថ្ងៃនេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ដោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តឧត្តរមានជ័យ និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ ដែលជាដៃគូរបស់យើង។ ខ្ញុំសង្ឃឹមថាបន្ទាប់ពីបញ្ចប់ គម្រោងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីអោយប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅរួច។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ **សូមអរគុណ!**